# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
## KINGDOM OF CAMBODIA
## Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ០២៦២ ព.ណ.....ស.ព.ក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១១

**<u>សូមគោរពជូន</u>**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងទេសចរណ៍**

**លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**ឯកឧត្តមអគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកគយ និងរដ្ឋាករកម្ពុជា**

**ឯកឧត្តម នាយកសាលាភូមិន្ទរដ្ឋបាល**

**<u>កម្មវត្ថុ</u>:** សំណើសុំអញ្ជើញ ឯកឧត្តម លោកជំទាវ ជាសមាជិករបស់គណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្ដប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ចូលរួមកិច្ចប្រជុំលើកទី ៦ នៅក្រសួងពាណិជ្ជកម្ម ។

**<u>ជូនភ្ជាប់</u>:** របៀបវារៈនៃកិច្ចប្រជុំ និងឯកសារពិភាក្សា។

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា ដើម្បីជំរុញការអនុវត្ត Trade SWAp ឱ្យមានសន្ទុះតាមការគ្រោងទុក ក្រសួងពាណិជ្ជកម្មសូមអញ្ជើញសមាជិករបស់គណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគីនិងសម្របសម្រួលអភិក្រមគ្របដណ្ដប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) ***<u>ចូលរួមប្រជុំពិនិត្យ និងវាយតម្លៃសម្រេចលើគម្រោងយុទ្ធសាស្ត្រចំនួនបីកញ្ចប់ដែលស្ថិតនៅក្នុងរបាយការណ៍នៃ</u>*** *<u>Mid Term Review</u>* ***<u>ដើម្បីសម្រេចបានតាមការកំណត់ឱ្យគម្រោង</u>*** *<u>TDSP</u>* ***<u>អនុម័តសម្រេចបានយ៉ាងហោចណាស់ចំនួនបីនៅដំណាច់ខែមករានេះ រួចស្នើមកសុំការគាំទ្រផ្នែកហិរញ្ញវត្ថុមុន នឹងដាក់</u>***

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Phone/Facsimile: (855)-23 866 469

***ជូនអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងទៅនឹងពាណិជ្ជកម្មដើម្បីសម្រេច និងអនុវត្តន៍*** ។

កិច្ចប្រជុំនេះនិងប្រព្រឹត្តទៅ នៅ**ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១១ នៅសាលប្រជុំនៃក្រសួងពាណិជ្ជកម្ម អាគារ ១៩-៦១ ផ្លូវ ១១៣ សង្កាត់ទឹកថ្លា ខ័ណ្ឌសែនសុខ រាជធានីភ្នំពេញ វេលាម៉ោង ១៤:៣០ នាទីល្ងាច** ក្រោមអធិបតីភាព ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ** មេត្តាចាត់បញ្ជូនឯកឧត្តម លោកជំទាវ ជាសមាជិកនៃគណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តន៍មូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្រប ដណ្តប់លើវិស័យពាណិជ្ជកម្មចូលរួមប្រជុំតាមកាលកំណត់ខាងលើដោយអនុគ្រោះ ។

សូម **ឯកឧត្តម លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

***ចម្លងជូន :***

- ខុទ្ទកាល័យ ឯកឧត្តមទេសរដ្ឋមន្ត្រី
- ឯកឧត្តម ប៉ាន សូរស័ក្តិ
- ឯកឧត្តម សុខ សុភ័ក្រ
- ឯកសារ-កាលប្បវត្តិ

***ទំនាក់ទំនងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ :***

ទូរស័ព្ទ : ០១៧ ៩៧៧ ៦៩៦

: ០៩២ ៨០៨ ២៦៨

អ៊ីមែល : seng.ramy@gmail.com
mollyhean7@yahoo.com